ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សាលក្រមរដ្ឋប្បវេណី

លេខ ១២-គ- ចុះថ្ងៃទី២០

ខែកុម្ភៈ ឆ្នាំ២០២០

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨៣៨ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើមចោទឈ្មោះ [redacted] រ័ត្ន ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ តន្ត្រីករភ្លេងបុរាណខ្មែរ ទីលំនៅ [redacted] ។

មានមេធាវីឈ្មោះ [redacted] ជាអ្នកតំណាងដោយអាណត្តិ។

ចុងចម្លើយឈ្មោះ [redacted] អ៊ីម ភេទស្រី អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មការនីរោងចក្រ ទីលំនៅ [redacted]

## អង្គហេតុ និង ចំណុចវិវាទ

១. **ការទាមទាររបស់គូភាគី**

ដើមចោទទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ ៖

- សុំឈប់រស់នៅជាអនីតិសង្វាស់ពីចុងចម្លើយ ។
- សុំបែងចែកទ្រព្យសម្បត្តិរួម។
- ផ្តល់សិទ្ធិមានអំណាចមេបាលើកូនទាំង៣នាក់ ឲ្យទៅចុងចម្លើយ។

២. **អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

ដើមចោទបានប្ដឹងថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងចុងចម្លើយត្រឹមត្រូវតាមទំនៀមទំលាប់ខ្មែរ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ទេ។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ពួកខ្លួនមានកូន ០៣នាក់ គឺ១/ឈ្មោះ [redacted] **សោភា** ភេទប្រុស អាយុ ១៥ឆ្នាំ ២/ឈ្មោះ [redacted] **សុខគា** ភេទស្រី អាយុ ១៣ឆ្នាំ និង៣/ឈ្មោះ [redacted] **សុខគៀង** ភេទស្រី អាយុ ៩ឆ្នាំ។ ទ្រព្យ សម្បត្តិរួមមានអចលនវត្ថុចំនួន២កន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០៨០១០៦-០៩១៦ និងលេខ ០៨០៨០១០៦-០២៨២ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥។ ក្នុង



Scanned with CamScanner

អំឡុងពេលរួមរស់នៅជាមួយគ្នា ខ្លួនមានមុខរបរជាអ្នកសិល្បៈ និងជាមន្ត្រីរាជការ ចំណែកឯចុងចម្លើយជាមេផ្ទះ និងថែរក្សាកូនៗ។

៣. **អំពីការថ្លែងការណ៍របស់ភាគី**

-ដើមចោទឈ្មោះ [redacted] **វ័ត្ន** អះអាងដូចចំណុចទី១ (ការទាមទាររបស់ដើមចោទ) និងទី២ (អង្គហេតុដែលជាមូលហេតុនៃការទាមទារ) ខាងលើ។

-ចុងចម្លើយឈ្មោះ [redacted] **អុឹម** អះអាងថា ខ្លួនឯកភាពឈប់រស់នៅជាអនីតិសង្វាស់ជាមួយដើមចោទ។ ចំណែកទ្រព្យសម្បត្តិរួមមាន ដី,ផ្ទះចំនួន ២កន្លែង ដូចការអះអាងរបស់ដើមចោទ ហើយខ្លួនសុំទុកឲ្យកូនទាំង៣ គ្រប់គ្រង ថែរក្សារហូតដល់ពួកគេពេញវ័យ និងទាមទារអាហារកិច្ចចិញ្ចឹមកូនក្នុងម្នាក់១០០$us ក្នុង១ខែ ហើយខ្លួនសុំទទួលធ្វើជាអ្នកមានអំណាចមេបាលើកូនទាំង៣នាក់នេះ។

-ដើមចោទឈ្មោះ [redacted] **វ័ត្ន** អះអាងថា ខ្លួនយល់ព្រមប្រគល់ដី,ផ្ទះដែលមានលេខ ០៨០៨០១០៦-០២៨២ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ឲ្យទៅកូនទាំង៣ គ្រប់គ្រង ថែរក្សារហូតដល់ពួកគេពេញវ័យ រីឯដី,ផ្ទះដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៨០៨០១០៦-០៤១៦ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ សុំលក់យកប្រាក់មកបែងចែកជាពីរចំណែកស្មើៗគ្នា។ ចំពោះអាហារកិច្ចចិញ្ចឹមកូន គឺមានលទ្ធភាពក្នុងម្នាក់៥០$us ក្នុង១ខែប៉ុណ្ណោះ។

៤. **អំពីភស្តុតាង**

-បានឃើញសេចក្តីចម្លងសំបុត្រកំណើតចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤ របស់មន្ត្រីអត្រានុកូលដ្ឋានបែកចាន (ចម្លងចេញពីសៀវភៅកំណើតលេខ ០១/២០០៤ សំបុត្រកំណើតលេខ ១៤ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤) របស់ឈ្មោះ [redacted] **សោភា** ភេទប្រុស ។

-បានឃើញសំបុត្រកំណើតលេខ ១៧៦ សៀវភៅកំណើតលេខ ០៤ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦ របស់មន្ត្រីអត្រានុកូលដ្ឋានបែកចាន របស់ឈ្មោះ [redacted] **សុខគា** ភេទស្រី។

-បានឃើញសំបុត្រកំណើតលេខ ១៦១ សៀវភៅកំណើតលេខ ០៤ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ របស់មន្ត្រីអត្រានុកូលដ្ឋានបែកចាន របស់ឈ្មោះ [redacted] **សុខគៀង** ភេទស្រី។

-បានឃើញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៨០៨០១០៦-០៤១៦ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

-បានឃើញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០៨០១០៦-០២៨២ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

## **សំអាងហេតុ**

***ឆ្លងតាមលទ្ធផលនៃកាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា***

**អំពីការឈប់រស់នៅជាអនីតិសង្វាស់**

១/. គូភាគីគឺជាប្តីប្រពន្ធនឹងគ្នា ដែលបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមទំនៀមទំលាប់ ប្រពៃណីខ្មែរ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីបញ្ជាក់ពីទំនាក់ទំនងតាមផ្លូវច្បាប់ទេ។ ការរួមរស់នៅជាមួយគ្នាដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះ ហៅថាការរស់នៅបែបអនីតិសង្វាស់។



Scanned with CamScanner

ដោយសារតែពុំមានច្បាប់ចែង ដែលអាចឲ្យតុលាការយកមកអនុវត្តចំពោះការទាមទាររបស់ដើមចោទសុំឈប់រស់នៅជាអនីតិសង្វាស់ពីចុងចម្លើយ ដូច្នេះតុលាការមិនទទួលស្គាល់ការទាមទារនេះទេ ក៏ប៉ុន្តែគូភាគីអាចបង្ហាញឆន្ទៈបែកបាក់គ្នាបាន ដោយពុំចាំបាច់មានអន្តរាគមន៍ពីតុលាការឡើយ។

**អំពីការសម្រេចអ្នកមានអំណាចមេបា**

២/. យោងតាមសេចក្តីចម្លងសំបុត្រកំណើតចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤ (ចម្លងចេញពីសៀវភៅកំណើតលេខ ០១/២០០៤ សំបុត្រកំណើតលេខ ១៤ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៤), សំបុត្រកំណើតលេខ ១៧៦ សៀវភៅកំណើតលេខ ០៤ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០៦ និងសំបុត្រកំណើតលេខ ១៦១ សៀវភៅកំណើតលេខ ០៤ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១១ របស់មន្ត្រីអត្រានុកូលដ្ឋានបែកចាន បញ្ជាក់បានថា ឈ្មោះ [redacted] **សោភា**, ឈ្មោះ [redacted] **សុខគា** និងឈ្មោះ [redacted] **សុខគៀង** គឺជាកូនរបស់គូភាគី។

៣/. ដើមចោទសុំគ្រប់គ្រង ថែរក្សាកូនទី៣ វិញ ពីព្រោះបន្ទាប់ពីខ្លួនបានយល់ព្រមដូចខាងលើមក ឃើញថា ចុងចម្លើយមិនបានបីបាច់ ថែរក្សាកូនទី៣ បានពេញលេញទេ ដូចជាអនាម័យ ការសិក្សាមិនល្អប្រសើរ គ្រូទូរស័ព្ទមកណែនាំជាញឹកញាប់ ជាអាទិ៍ ចំណែកកូនបងក៏មានបញ្ហាដែរ។

ចុងចម្លើយអះអាងថា មិនមានបញ្ហាទាំងស្រុងនោះទេ ក៏ប៉ុន្តែខ្លួនបានឲ្យទៅសាលារៀនរហូត។ ចំណែកកូនបង មានបញ្ហាកើតឡើង មិនអាចបន្ទោសអ្នកណាបានទេ។

៤/. តុលាការពិនិត្យឃើញថា ស្ថានភាពរបស់គូភាគីមានលក្ខណៈប្រហាក់ប្រហែលគ្នាទាំងចំណូល និងកំរិតសិក្សា ជាអាទិ៍ ។

តាមការសាកសួរលើកូនទី៣ ឈ្មោះ [redacted] **សុខគៀង** នាកាលបរិច្ឆេទ បានអះអាងថា ខ្លួនសុំរស់នៅជាមួយម្តាយ។ តាមមាត្រា ២២ ចំណុច៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងហានៈបុគ្គល (អនុវត្តក្នុងលក្ខណៈស្រដៀង)។

ដូច្នេះដើម្បីកូនទាំង៣ នៅជួបជុំបងប្អូនបាន តុលាការមិនទទួលស្គាល់ការទាមទាររបស់ដើមចោទទេ។

តាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី, មាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងហានៈបុគ្គល (អនុវត្តក្នុងលក្ខណៈស្រដៀង)។

**អំពីទ្រព្យសម្បត្តិរួម**

៥/. តាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៨០៨០១០៦-០៨១៦ និងលេខ ០៨០៨០១០៦-០២៨២ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ឃើញថា អចលនទ្រព្យក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុទាំង២ គឺ គូភាគីជាម្ចាស់កម្មសិទ្ធិរួមគ្នា។

គូភាគីទទួលស្គាល់ថា ដី,ផ្ទះមានក្បាលដីលេខ ២៨២ ដែលរស់នៅសព្វថ្ងៃ មានតម្លៃថ្លៃជាងដី,ផ្ទះមានក្បាលដីលេខ ៨១៦។

៦/. ដោយហេតុថា តុលាការទទួលស្គាល់អ្នកមានអំណាចមេបាដូចបានសំអាងហេតុខាងលើ និងដើម្បីកូនទាំង៣ មានទីលំនៅស្នាក់នៅបានសមរម្យ ក្នុងឧត្តមប្រយោជន៍របស់



Scanned with CamScanner

កុមារផង តុលាការមិនទទួលស្គាល់នូវការទាមទាររបស់គូភាគី ដូចដែលគូភាគីបានថ្លែងការណ៍ខាងលើនោះទេ។ តាមមាត្រា ៩៨០ កថាខណ្ឌ២ ចំណុច ខ វាក្យខណ្ឌ២ នៃក្រមរដ្ឋប្បវេណី។

-សាលក្រមនេះប្រកាសនៅសាលសវនាការជាសាធារណៈ នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២០។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១-/ លើកចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] **វ័ន្ត** សុំឈប់រស់នៅជាអនិតិសង្វាស់ពីចុងចម្លើយឈ្មោះ [redacted]**អ៊ឹម** ដោយមូលហេតុផ្ទុយច្បាប់ ។

២-/ ចុងចម្លើយឈ្មោះ [redacted] **អ៊ឹម** គឺជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **សោភា** ភេទប្រុស កើតនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩, ឈ្មោះ [redacted] **សុខតា** ភេទស្រី កើតនៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៦ និងឈ្មោះ[redacted] **សុខគៀង** ភេទស្រី កើតនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

៣/- បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] **វ័ន្ត** បង់អាហារកិច្ចចិញ្ចឹម ថែរក្សាកូន ក្នុងម្នាក់ចំនួន ៥០(ហាសិប)ដុល្លារអាមេរិក ក្នុង១ខែ ទៅឲ្យចុងចម្លើយឈ្មោះ [redacted] **អ៊ឹម** រហូតកូននីតិភាព។

៤/- ប្រគល់ទៅឲ្យដើមចោទ និងឲ្យដើមចោទឈ្មោះ[redacted] **វ័ន្ត** ធ្វើលទ្ធកម្ម(ចុះបញ្ជី) លើដី, ផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ០៨០៨០១០៦-០៩១៦ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥។

៥/- ប្រគល់ទៅឲ្យចុងចម្លើយ និងឲ្យចុងចម្លើយឈ្មោះ [redacted] **អ៊ឹម** ធ្វើលទ្ធកម្ម(ចុះបញ្ជី) លើដី, ផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០៨០១០៦-០២៨២ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥។

៦/- ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ ។

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner